# ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច  ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# និង  ការអភិវឌ្ឍន៍វិស័យឯកជន

## សេចក្តីថ្លែងការធ្វើឡើងដោយដៃគូអភិវឌ្ឍន៍របស់កម្ពុជា

## នៅឯវេទិកាសហប្រតិបត្តិការ និង អភិវឌ្ឍន៍កម្ពុជាលើកទី ១

## ភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧

**ឯកឧត្តម  លោកជំទាវ  លោក  លោកស្រី**

នេះគឺជាកិត្តិយសដែលដៃគូអភិវឌ្ឍន៍បានចូលរួមក្នុងវេទិកាសហប្រតិបត្តិការ និង អភិវឌ្ឍន៍កម្ពុជាលើកទី ១ និង ផ្តល់ចំណាប់អារម្មណ៍ខ្លះៗ អំពីកំណែទំរង់លើការអភិវឌ្ឍន៍ និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និង ការអភិវឌ្ឍន៍វិស័យឯកជន (PSD) ។

ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចជាទូទៅបានល្អប្រសើរ  ចាប់តាំងពីពេលដែលដៃគូអភិវឌ្ឍន៍  និង  រាជរដ្ឋាភិបាលបានជួបនៅឯការជួបប្រជុំក្រុមពិគ្រោះយោបល់ប្រហែលជាជាងមួយឆ្នាំបន្តិចមុននេះ  ។ កំណើននៅតែខ្ពស់ណាស់ ហើយអតិផរណាទាប  ចំណូលរដ្ឋបានកើនឡើងយ៉ាងច្រើន  ថវិកាបានកំពុងផ្តោតទៅលើគោលដៅអភិវឌ្ឍន៍អាទិភាពស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងតែដំណើរការ  ផ្តល់ការជឿទុកចិត្តចំពោះថវិកា នៅពេលដែលបរិស្ថានពាណិជ្ជកម្មកំពុងត្រូវបានកែលំអតាមរយៈកិច្ចផ្តួចផ្តើមនានាក្នុងការអភិវឌ្ឍន៍វិស័យឯកជន ។

ដៃគូអភិវឌ្ឍន៍កោតសរសើររាជរដ្ឋាភិបាលក្នុងកិច្ចខំប្រឹងប្រែងអនុវត្តគោលនយោបាយក្នុងវិស័យខាងលើ  និងជ័យជំនះដ៏ច្បាស់លាស់ដែលទទួលបាន  ។  កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោកសព្វថ្ងៃ ដែលលទ្ធផលនៃការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង កំណែទំរង់រចនាសម្ព័ន្ធសេដ្ឋកិច្ចប្រកបដោយរឹងមាំ  និង  ប្រុងប្រយ័ត្ន  ហើយនឹងការគាំទ្រយ៉ាងខ្លាំងក្លាទាំងបច្ចេកទេសនិងហិរញ្ញវត្ថុពីសំណាក់ដៃគូអភិវឌ្ឍន៍  ។  លើសពីនេះទៅទៀត  ដូចបានចង្អុលបង្ហាញ  ដោយរបាយការណ៍អភិវឌ្ឍន៍ និង សមភាពរបស់ធនាគារពិភពលោក ផលប្រយោជន៍នៃកំណើននេះ បានចែកចាយយ៉ាងស្មើគ្នាជាបង្គួរក្នុងកំឡុងឆ្នាំ ១៩៩៧ រហូតដល់ឆ្នាំ ២០០៤ ។ នេះគឺជាដំណឹងល្អ ។

ការកែទំរង់លើម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការអភិវឌ្ឍន៏វិស័យឯកជនបានរួមចំណែកអោយមានលទ្ធផលជាវិជ្ជមានទាំងផ្ទាល់ និង ទាំងប្រយោល ។ កំណែទំរង់ទាំងនោះ ផ្តល់នូវបរិស្ថានដ៏មានស្ថិរភាព និងអាចទាយទុកមុនបានដែលចាំបាច់សំរាប់ការអភិវឌ្ឍន៏ ដើម្បីដោះស្រាយអភិបាលកិច្ចក្នុងការគ្រប់គ្រងធនធានសាធារណៈ និង ជួយបញ្ជូនធនធានទាំងនោះ ប្រកបដោយមានប្រសិទ្ធភាព និង មានតម្លាភាពឆ្ពោះទៅការអនុវត្តបានគោលដៅអភិវឌ្ឍន៏សហសវត្សរបស់ប្រទេសកម្ពុជា (CMDGs) ហើយកំណែទំរង់ទាំងនេះបានពង្រីកមូលដ្ឋានសកម្មភាពសេដ្ឋកិច្ច និង ពង្រឹងចំណងផ្សារភ្ជាប់រវាងកំណើន និង ការកាត់បន្ថយភាពក្រីក្រ ។

ភ្ជាប់ជាមួយនឹងការរីកដុះដាលនៃទ្រព្យសម្បត្តិសេដ្ឋកិច្ច គឺការសង្ឃឹម និង បំណងប្រាថ្នាដ៏ខ្ពស់ជាងមុនក្នុងការដោះស្រាយបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាកំណែទំរង់ដ៏ពិបាកៗដែលមិនរីកចំរើនឆាប់រហ័សដូចបានគ្រោងទុក។ មិនត្រូវអោយបាត់ការយកចិត្តទុកដាក់ចំពោះហេតុដែលថា ភាពក្រីក្រនៅតែមានរាយប៉ាយ ទោះបីជាមានការអភិវឌ្ឍន៏ក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ ហើយភាពក្រីក្រខ្លាំងមានជាអន្លើៗនៅតំបន់ជនបទ ចំណែកឯគម្លាតចំណូលរវាងអ្នកមាន និង អ្នកក្រ នៅតែមានធំ ។ បញ្ហាថ្មីៗកើតលេចឡើងរួមទាំងជាពិសេសការអភិវឌ្ឍន៏ក្របខ័ណ្ឌច្បាប់ និង គោលនយោបាយ ដើម្បីធ្វើអោយបានអតិប្បរមានូវប្រយោជន៏នៃការរកឃើញប្រេងរបស់កម្ពុជានៅពេលដែលហានិភ័យត្រូវគ្រប់គ្រង ។

## ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចនៅពេលថ្មីៗនេះ

កំណើនរបស់សេដ្ឋកិច្ចកម្ពុជា គួរអោយកោតសរសើរ ។ ផលទុនជាតិ (គិតតាមតំលៃថេរ) ត្រូវបានប៉ាន់ប្រមាណថា បានកើនដល់ 10¾ ភាគរយក្នុងឆ្នាំ 2006 ដែលនាំមុខដោយកំណើនប្រហែលជា 20ភាគរយនៅក្នុងវិស័យទេសចរណ៏ នាំចេញសំលៀកបំពាក់ និង សំណង់ ។ ផលិតផលកសិកម្មបានរីកដុះដាលដោយសារតែការធ្វើអោយសម្បូរបែបនៃដំណាំកសិកម្មទៅកាន់ការផលិតដំណាំសំរាប់លក់យកប្រាក់ ការបង្កើនទិន្នផល និង លក្ខខណ្ឌអាកាសធាតុអំណោយផល ។ សេវាកម្ម ជាពិសេសផ្នែកហិរញ្ញវត្ថុ និង ទូរគមនាគមន៏បានរួមចំណែកកាន់តែខ្លាំងឡើងៗ ហើយការវិនិយោគផ្ទាល់ពីបរទេសមានសភាពខ្លាំងក្លា ។ និន្នាការទាំងនេះកំពុងបន្តជាទូទៅនៅក្នុងឆមាសទីមួយនៃឆ្នាំ 2007 ។

អតិផរណានៅតែស្ថិតនៅក្នុងកំរិតលេខមួយខ្ទង់ទាប ហើយនៅចុងឆ្នាំ ២០០៦ មានកំរិតទាបណាស់គឺ 2¾ ភាគរយដែលឆ្លុះបញ្ចាំងការអនុវត្តគោលនយោបាយរូបិយវត្ថុដ៏រឹងមាំនៅតែបន្ត ។ ការកើនឡើងបន្តិចដល់ 4 ភាគរយក្នុងឆ្នាំ 2007 ឆ្លុះបញ្ចាំងជាចំបងនូវការឡើងថ្លៃត្រី និង ឥទ្ធិពលនៃការបញ្ជូនថ្លៃនៃតំលៃប្រេងអន្តរជាតិដែលខ្ពស់ជាងមុន ទោះបីជាសំពាធអតិផរណាជាទូទៅហាក់ដូចជានៅទ្រឹង ។ កំណើនយ៉ាងខ្លាំងក្នុងផ្នែកនាំចេញសំលៀកបំពាក់ និង ចំណូលពីទេសចរណ៏ធ្វើអោយមានការធ្លាក់ចុះនៃឱនភាពគណនីចរន្តក្រៅប្រទេស (មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ) ដល់ 7¼ភាគរយ នៃផលទុនជាតិ ក្នុងឆ្នាំ 2006 និង ជួយបង្កើនទុនបំរុងអន្តរជាតិដល់លើសពី 1.2ពាន់លានដុល្លាអាមេរិក នៅដើមឆ្នាំ 2007 ។

ការគ្រប់គ្រងគោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្នបានគាំទ្រដល់ការអនុវត្តម៉ាក្រូសេដ្ឋកិច្ចដ៏ខ្លាំង ។ ដោយសារចំណូលខ្លាំងក្លា និង ចំណាយយឺត ឱនភាពជាទូទៅរបស់រដ្ឋាភិបាលរួមតូចក្នុងឆ្នាំ 2006 ចំណាយកកស្ទះត្រូវបានថយចុះយ៉ាងច្រើន និង បញ្ញើរបស់រដ្ឋាភិបាលនៅក្នុងប្រព័ន្ធធនាគារកើនឡើង ។ ចំណូលរបស់រដ្ឋាភិបាលកើនលើសពីថវិកាដោយសារសកម្មភាពសេដ្ឋកិច្ចដ៏ខ្លាំងក្លា និង ការកែលំអរដ្ឋបាលចំណូល គាំទ្រដោយកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការអនុវត្តការប្រមូលចំណូលដើមឆ្នាំ 2007 កំពុងតែកើនឡើង ការប៉ានស្មានដំបូងបង្ហាញថាចំណូលពន្ធកើនបានប្រហែលមួយភាគបី ចាប់ពីដើមឆ្នាំរហូតដល់ខែមេសាបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ហើយគោលដៅចំណូលក្នុងថវិកាសង្ឃឹមថានឹងសំរេចបានលើសយ៉ាងច្រើន ។ ប៉ុន្តែចំណាយរបស់រដ្ឋាភិបាលត្រូវបានរិតបន្តឹង ។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកដែលត្រូវការយ៉ាងខ្លាំងនោះ កើនឡើងតែបន្តិចក្នុងឆ្នាំ 2006 ហើយការលំបាកជាដំបូងនានាក្នុងការអនុវត្តនីតិវិធីចំណាយថ្មីបានពន្យឿតចំណាយក្នុងក្រសួងអគ្គិភាពនានានៅដើមឆ្នាំ 2007 ។ ការដោះស្រាយការលំបាកខាងលើយ៉ាងឆាប់រហ័ស គួរតែបង្កើនល្បឿនចំណាយសំរាប់រយៈពេលដែលនៅសល់ក្នុងឆ្នាំ ។

វិស័យធនាគារបន្តរីកដុះដាលយ៉ាងលឿន ទាំងបញ្ញើ និង កំចី កើនឡើងប្រហែល 40 ភាគរយ ។ កំណើនក្នុងប្រព័ន្ធធនាគារកំពុងសំរួលការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ឆ្លុះបញ្ចាំងការកើនឡើងនៃទំនុកចិត្ត ។

## ការប្រមើលមើលក្នុងដំណាក់កាលខ្លី និង បញ្ហាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាគន្លឹះ

ការប្រមើលមើលសេដ្ឋកិច្ចគឺល្អ ។ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្នបានផ្តល់នូវស្ថិរភាព ហើយស្ថិរភាពនេះបានបង្កើនការទុកចិត្ត និង ការវិនិយោគផ្ទាល់ពីបរទេស និង គាំទ្រការអនុវត្តម៉ាក្រូសេដ្ឋកិច្ចដ៏ខ្លាំង ។ និន្នាការកំណើនជាទូទៅដែលបានឃើញនៅក្នុងឆ្នាំ 2006 ត្រូវគ្រោងថានឹងបន្តក្នុងដំណាក់កាលខ្លី ជាមួយនឹងការវិនិយោគបរទេស ដែលនៅតែមានកំរិតខ្ពស់ នាំអោយមានកំណើនសេដ្ឋកិច្ចប្រហែល 9 ភាគរយ នៃឆ្នាំ 2007 និង ប្រហែល 7½ ភាគរយ ក្នុងកំឡុងរយៈពេលមធ្យម ។ ដោយសន្មត់ថា តំលៃប្រេងអន្តរជាតិមានលំនឹងជាទូទៅ អតិផរណានឹងស្ថិតនៅក្នុងលេខមួយខ្ទង់ទាប ។

បរិស្ថានវិជ្ជមាននេះផ្តល់នៅលក្ខខណ្ឌដ៏ប្រពៃដើម្បីជំរុញសារជាថ្មីឡើងវិញផ្នែកនានានៃកំណែទំរង់ដែលមិនទាន់បានរីកចំរើនឆាប់រហ័សនៅឡើយ និង ដើម្បីដោះស្រាយហានិភ័យជាគន្លឹះមួយចំនួនដែលមានចំពោះការប្រមើលមើល រួមទាំងការរារាំងដល់ការកាត់បន្ថយភាពក្រីក្រដ៏ទូលំទូលាយ និងជ្រៅជាងមុនផងនោះ ក្នុងការសំរេចអោយបានគោលដៅអភិវឌ្ឍន៍ សហសវត្សរបស់កម្ពុជា ។ ភាពប្រឈមជាគន្លឹះមានដូចតទៅ :

- ពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច ។ ជាពិសេសមូលដ្ឋាននៃការនាំចេញតូចចង្អៀតនៅតែមានភាពងាយស្រួលរងគ្រោះ ដោយឥទ្ធិពលនៃការវិវត្តន៍ក្នុង និង ក្រៅប្រទេស ។ ទោះបីជាផលិតកម្មកាត់ដេរហាក់ដូចជាមានភាពមាំទាំ ភាពប្រកួតប្រជែងក្នុងវិស័យនេះអាចមានរយៈពេលខ្លី ។ ការចូលជាសមាជិករបស់វៀតណាម ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និង ការលើកលែងនៃវិធានការណ៍ ការពារនានាមកលើប្រទេសចិន គឺជាហានិភ័យដ៏ចំបង ។

- បង្កើនទិន្នផលកសិកម្ម ។ កសិកម្មដែលសំខាន់សំរាប់ប្រជាជនភាគច្រើននៅតែងាយរងគ្រោះដោយសារឥទ្ធិពលនៃអាកាសធាតុ ទោះបីមានការកែលំអផ្នែកប្រព័ន្ធស្រោចស្រពក៏ដោយ ។

- ថែរក្សាសន្ទុះក្នុងការបង្កើនចំណូលរបស់រដ្ឋាភិបាល ដើម្បីអោយទទួលបានចំណាយ ប្រកបដោយគុណភាព និង បរិមាណសំរាប់ការកាត់បន្ថយភាពក្រីក្រ។ មានភាពជឿនលឿនល្អក្នុងឆ្នាំ 2007 ទោះបីជាចំណូលនៅតែទាបបើប្រៀបធៀបទៅនឹងផលទុនជាតិ និងប្រទេសដទៃទៀត ។ ការកើនឡើងដោយចីរភាពនៃចំណូលនឹងបន្តបានមកពីការកែលំអផ្នែករដ្ឋបាលចំណូល និង ការចាប់បង្ខំ ហើយចំណូលគួរតែត្រូវតំរង់ទិសទៅកាន់គំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ កំណែទំរង់ប្រាក់បៀវត្សនៃសេវាសាធារណៈជាយុទ្ធសាស្ត្រ និង វិស័យអាទិភាពដែលបង្ហុលបង្ហាញនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដូចជាវិស័យសុខាភិបាល និង អប់រំ ។

- ការពារភាពរឹងមាំរបស់ប្រព័ន្ធធនាគារ ។ ល្បឿននៃកំណើនយ៉ាងលឿនក្នុងអន្តរនីយកម្មហិរញ្ញវត្ថុតំរូវអោយមានការត្រួតពិនិត្យធនាគារដ៏រឹងមាំ ដើម្បីធានាថា ធនាគារទាំងឡាយថ្លឹងថ្លែងហានិភ័យកំចីទាំងអស់ត្រឹមត្រូវរួមទាំងហានិភ័យទាក់ទងនឹងការឡើងថ្លៃដីដ៏លឿន ។

- កែលំអស្ថាប័ន និង សមត្ថភាពក្នុងរដ្ឋាភិបាល មួយផ្នែកដោយដោះស្រាយបញ្ហាពុករលួយ និង ពង្រឹងសេវាសាធារណៈ ។ មានគម្លាតដ៏ធំរវាងល្បឿនលឿននៃការផ្លាស់ប្តូរសេដ្ឋកិច្ច និង ដំណើរការនៃការកសាងស្ថាប័ន និង សមត្ថភាពនៅក្នុងរដ្ឋាភិបាលដែលជាធម្មតាយឺតជាង ។ ការស្រាវជ្រាវជាអន្តរជាតិបង្ហាញថា កត្តាជាគន្លឹះមួយនៅក្នុងកំណើនសេដ្ឋកិច្ចរបស់ប្រទេសដែលមានសេដ្ឋកិច្ចទទួលបានជោគជ័យនៅក្នុងតំបន់ គឺជាភាពដ៏រឹងមាំ និង គួរអោយជឿទុកចិត្តបាននៃការគោរពច្បាប់ ។ ក្នុងបរិបទនេះ កែលំអអភិបាលកិច្ចវិស័យសាធារណៈរបស់កម្ពុជា ជាពិសេសតាមរយៈការពង្រឹងការគ្រប់គ្រងវិស័យសារពើពន្ធ និងហិរញ្ញវត្ថុ និង កាត់បន្ថយអំពើពុករលួយថែមទាំងបង្កើនការប្រកួតប្រជែងនឹងគាំទ្រស្ថេរភាព កែលំអបរិយាកាសវិនិយោគ និង បង្កអោយមានភាពជឿនលឿនបន្ថែមទៀតក្នុងការកាត់បន្ថយភាពក្រីក្រ ។

ក្នុងដំណាក់កាលវែងជាង ផលិតកម្មប្រេងអាចបង្កើនចំណូលជាតិដ៏ច្រើន ហើយចំណូលសារពើពន្ធបានមកពីប្រេងនឹងផ្តល់ហិរញ្ញប្បទានដ៏សំខាន់សំរាប់ចំណាយអភិវឌ្ឍន៍ចំពោះអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដោយភាពមិនពិតប្រាកដជុំវិញក៏រិតនៃប្រេងបំរុង និង ពេលវេលានៃផលិតកម្មប្រេង រដ្ឋាភិបាលគួរជៀសវាងការធ្វើការវិនិយោគលើគំរោងហេដ្ឋារចនាសម្ព័ន្ធធំៗ បំរើអោយវិស័យប្រេង និងត្រូវប្រុងប្រយ័ត្នជាមួយនឹងកំចីពាណិជ្ជកម្ម ក្នុងការរំពឹងទុកចំពោះភាពមិនពិតប្រាកដរបស់ចំណូលពីប្រេង ។

ភាពជឿនលឿន ក្នុងការបង្កើតក្របខ័ណ្ឌគោលនយោបាយ និង ច្បាប់សំរាប់វិស័យប្រេង និង សំរាប់ការគ្រប់គ្រងចំណូលពីប្រេងក្នុងពេលអនាគត និង បង្កើនលទ្ធភាពនៃផលិតកម្មពាណិជ្ជកម្មដ៏រួសរាន់ និងការប្រើប្រាស់ធនធានដោយអតិបរមា ។ មូលដ្ឋានគ្រឹះជាគន្លឹះ គឺពង្រឹងរបបពន្ធដាររបស់ប្រេង និង ដាក់របបនេះនៅក្នុងច្បាប់សារពើពន្ធបច្ចុប្បន្ន ។ ដៃគូអភិវឌ្ឍន៍ក៏លើកទឹកចិត្តអោយរាជរដ្ឋាភិបាលធ្វើអោយមានភាពជឿនលឿនលើការអនុម័តិគំនិតផ្តួចផ្តើម អំពីតម្លាភាពសំរាប់ឧស្សាហកម្មប្រមូលធនធាន (Extractive industries Transparency Initiative - EITI) ។

កំណើនសេដ្ឋកិច្ចដែលនៅតែខ្លាំងក្លាជាបន្ត ដែលត្រូវបានសង្ឃឹមទុកក្នុងរយៈកាលមធ្យមនិងរយៈកាលវែង ដាក់អោយបំណុលរបស់រដ្ឋាភិបាលនៅលើផ្លូវដែលមានចីរភាព ហើយរចនាសម្ព័ន្ធសម្បទានដ៏ខ្ពស់នៃកំចីរបស់កម្ពុជាបន្ថយហានិភ័យនៃភាពអាសន្នរបស់បំណុល ។ ទោះបីយ៉ាងនេះក៏ដោយ ហានិភ័យជាមធ្យមនៅតែមាន ជាពិសេសដោយសារកំរិតទាបនៃចំណូលរដ្ឋាភិបាលដែលមានបច្ចុប្បន្ន ។

ក្នុងបរិប័ទនេះ ការចាត់ថ្នាក់ឥណទានអធិបតេយ្យដែលទទួលបានថ្មីៗនេះ បើកទ្វារផ្លូវអោយរដ្ឋាភិបាលខ្ចីពីទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ។ នៅពេលដែលកំចីមួយចំនួនតូចដែលផ្អែកទៅលើការប្រាក់ពាណិជ្ជកម្មសំរាប់គំរោងរចនាសម្ព័ន្ធដែលចំណេញខ្ពស់សមស្របនឹងចីរភាពបំណុល ប៉ុន្តែកំចីនោះនឹងបង្កអោយមានចំណាយច្រើនក្នុងសេវាបំរើបំណុល និង បង្វែរធនធានរបស់រដ្ឋាភិបាលដ៏កំរពីសកម្មភាពដទៃទៀត ។ មធ្យោបាយដ៏ប្រុងប្រយ័ត្នមួយក្នុងកំចីពាណិជ្ជកម្មគឺត្រូវតែធានា ។

## ភាពក្រីក្រ សមភាព និង ការអភិវឌ្ឍន៍

កម្ពុជាបានធ្វើអោយមានភាពជឿនលឿនច្រើនក្នុងការកាត់បន្ថយភាពក្រីក្រក្នុងកំឡុងមួយទសវត្សកន្លងទៅនេះ ដោយអត្រានៃភាពក្រីក្រថយចុះពីការប៉ាន់ស្មានប្រហែល 47 ភាគរយ ក្នុងឆ្នាំ 1994 មកត្រឹម 35 ភាគរយ ក្នុងរយៈពេលដប់ឆ្នាំក្រោយមក ។ ប៉ុន្តែក្នុងកំឡុងពេលនោះ វិសមភាពក៏កើនឡើងយ៉ាងឆាប់រហ័ស ។ នេះគឺជាការព្រួយបារម្ភដែលយល់ឃើញដោយដៃគូអភិវឌ្ឍន៍នានា និង រាជរដ្ឋាភិបាលកម្ពុជា ។

ដូចបានចង្អុលបង្ហាញដោយរបាយការណ៍អភិវឌ្ឍន៍ និង សមភាពរបស់ធនាគារពិភពលោក ឆ្នាំ ២០០៧ ដែលរៀបរៀងឡើងសំរាប់វេទិកាសហប្រតិបត្តិ និង អភិវឌ្ឍន៍កម្ពុជានេះ ការកើនឡើងនៃវិសមភាពបានកើតឡើងក្នុងកំឡុងពេលដំបូង (1994-1997) នៃទសវត្ស ជាពិសេសនៅក្នុងតំបន់ជនបទ ។ នៅពាក់កណ្តាលទី 2 (1997-2004) នៃដំណាក់កាលនោះ វិសមភាពមិនមានការប្រែប្រួលធំដុំទេ ។ ផលប្រយោជន៍នៃកំណើននៅក្នុងដំណាក់កាលក្រោយនេះត្រូវបានបែងចែងស្មើគ្នាជាបង្គួររវាងអ្នកមាន និង អ្នកក្រ ។

ការប្រែប្រួល នៃការបែងចែកចំណូល និង ចំណាយរបស់កម្ពុជា សមស្របនឹងដំណើរការអន្តរកាលពីសេដ្ឋកិច្ច ផែនការមកសេដ្ឋកិច្ចទីផ្សារចំហ ដែលនាំមកជាមួយនូវការកើនឡើងនៃចំណូល ។ បំឡែងនេះបានលើកដំកើង ការចែកចាយធនធានអោយប្រសើរជាងមុន ការពង្រីកសកម្មភាពដែលមានផលប្រយោជន៍ និង ធ្វើអោយទូលាយនៃការបែងចែកចំណូល។ ជួយដោយកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និង ការកែលំអសមត្ថភាពក្នុងការអនុវត្តគោលនយោបាយសាធារណៈ កម្ពុជាទទួលបានសូចនាករសុខុមាលភាពដទៃទៀតដ៏ច្រើន ឧទាហរណ៍ ដូចជា សុខាភិបាលនិងការអប់រំ ដែលកាន់តែមានសមភាពបន្តិចម្តងៗ ។

ដៃគូអភិវឌ្ឍន៍ស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះរបកគំហើញខាងលើ ។ របកគំហើញទាំងនេះ ផ្តល់យោបល់ថា កម្ពុជាអាចបន្តដើរតាមផ្លូវនៃកំណើនខ្ពស់ និង មានសមភាព និង ការកាត់បន្ថយភាពក្រីក្រយ៉ាងលឿនក្នុងពេលអនាគត ក្នុងលក្ខខណ្ឌដែលមានការជ្រើសរើសគោលនយោបាយដែលមានភាពត្រឹមត្រូវ ។ ពិតណាស់ គឺមិនតំរូវអោយមានការផ្លាស់ប្តូរយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងស្រុងនេះទេ ។ ការកែលំអគោលនយោបាយសាធារណៈ និង ចំណាយសាធារណៈ អាចចងជាប់ផលចំណេញដែលទទួលបានមកដល់ពេលនេះ និង ធានាថាផលចំណេញទាំងនេះនឹងត្រូវចំលងតាមក្នុងពេលអនាគត ។

## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការជឿនលឿនយ៉ាងច្រើនក្នុងការសំរេចគោលដៅនៃជំហានទី 1 (Platform 1) ការធ្វើអោយថវិកាមានភាពជឿជាក់ ។ លើសពីនេះទៀត មានភាពជឿនលឿនយ៉ាងច្រើនក្នុងកិច្ចការត្រៀមបំរុងដ៏ចាំបាច់សំរាប់ជំហានទី 2 (គណនីភាពហិរញ្ញវត្ថុ) និង ជំហានទី 3 (ផ្សារភ្ជាប់គោលនយោបាយ និង ថវិកា) ។ នៅក៏រិតសរុប ការងារនេះបានជួយរាជរដ្ឋាភិបាលក្នុងការកែលំអការប្រមូលពន្ធក្នុងស្រុក ត្រួតពិនិត្យចំណាយ និង កាត់បន្ថយចំណាយក្នុងស្រុកដែលកកស្ទះ ។

កំណែទំរង់ជាប្រព័ន្ធដ៏ជាក់លាក់រហូតមកដល់បច្ចុប្បន្ននេះគឺមាន :

- ក្របខ័ណ្ឌគោលនយោបាយថវិកាជាយុទ្ធសាស្ត្រ ដែលមានការកែលំអ រួមទាំងការអភិវឌ្ឍន៍ក្របខ័ណ្ឌម៉ាក្រូសារពើពន្ធមួយ និង ការរៀបចំនៃការណែនាំសំរាប់ការកសាងផែនការអភិវឌ្ឍន៍ថវិកាជាយុទ្ធសាស្ត្រ ដោយក្រសួងសាមីនានា ។

- ពង្រឹងដំណើរការកសាងថវិកា រួមទាំងការតាក់តែងនៃប្រតិទិនថវិកាថ្មីដែលវែងជាងមុន អនុវត្តការចាត់ថ្នាក់ថវិកា និង មាតិកាគណនីដែលចុះសំរុងគ្នា ដាក់បញ្ចូលអោយប្រើប្រាស់យ៉ាងរួសរាន់ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង សាកល្បងថវិកាតាមកម្មវិធីនៅក្រសួងចំនួនប្រាំពីរ ។ ច្បាប់ថវិកាគោល បានធ្វើវិសោធនកម្ម ដើម្បីសំរបសំរួលជាមួយការផ្លាស់ប្តូរទាំងនេះ ។

- បង្កើនប្រសិទ្ធភាពក្នុងការអនុវត្តន៍ថវិកា រួមទាំងបន្តធ្វើអោយរលូន និងវិមជ្ឈការនៃដំណើរការសន្យាចំណាយ និង ការទូទាត់ចំណាយ ហើយការប្រើប្រាស់ប្រព័ន្ធធនាគារអោយបានទូលំទូលាយជាងមុន ។ ក្របខ័ណ្ឌច្បាប់សំរាប់លទ្ធកម្មត្រូវបានពង្រឹង ។ លើសពីនេះទៅទៀត ផ្នែកទីមួយនៃដំណើរការតាក់តែង និង ទិញប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ កំពុងតែដំណើរការ ។

- ការកែលំអការត្រួតពិនិត្យបរិស្ថាន រួមទាំងការត្រួតពិនិត្យផ្ទៃក្នុង និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

កំណែទំរង់ជាប្រព័ន្ធទាំងនេះ ត្រូវបានគាំទ្រដោយវិធានការកសាងស្ថាប័នមួយចំនួន រួមទាំងការបណ្តុះបណ្តាលជាចាំបាច់យ៉ាងទូលំទូលាយ និង សកម្មភាពកសាងជំនាញ ។ ជ័យជំនះជាគន្លឹះមួយ គឺការដាក់អោយមានគំនិតផ្តួចផ្តើមការផ្តល់បៀវត្សតាមការបំពេញការងារ (MBPI) នៅក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដែលទ្រទ្រង់ដល់ការកែលំអយ៉ាងច្រើនក្នុងការលើកទឹកចិត្ត ផលិតភាពការងារ ការគោរពពេលវេលា និង ការបំពេញការងារ ។

ដោយផ្អែកលើការវិភាគខាងលើនេះ ដៃគូអភិវឌ្ឍន៍មានទស្សនៈថា ទោះបីជាគោលដៅនៃសូចនាករត្រួតពិនិត្យរួមគ្នា (JMI) អំពីការបញ្ចប់នៃជំហានទី 1 មិនទាន់បានបំពេញពេញលេញនៅឡើយក៏ដោយ ក៏មានការជឿនលឿនយ៉ាងច្រើនឆ្ពោះទៅកាន់ការធ្វើអោយមានការកែលំអចំពោះជំនឿលើថវិកា ។

## ជំហានបន្ទាប់ក្នុងកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នៅឯការប្រជុំប្រចាំឆ្នាំរបស់កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញសាធារណៈ អ្នកដែលជាប់ជាក់ទិនទាំងឡាយបានព្រមព្រៀងថា ទោះបីជាមានភាពជឿនលឿនដ៏ល្អ ក៏នៅមានការងារដែលត្រូវធ្វើ ដើម្បីបញ្ចប់ជំហានទី 1 ។ បញ្ហាកំណែទំរង់ជាគន្លឹះដែលមិនទាន់ដោះស្រាយចប់ស្រេចបាច់មាន គឺ :

- កែលំអភាពគ្រប់ជ្រុងជ្រោយ និង សមាហរណកម្មនៃថវិកា
- កែលំអគោលនយោបាយប្រមូលចំណូល
- ធ្វើអោយសមស្របការគ្រប់គ្រងសាច់ប្រាក់ រួមមានផែនការសាច់ប្រាក់ ប្រមូលផ្តុំគណនីធនាគាររបស់រដ្ឋាភិបាល និង ការប្រើប្រាស់អោយបានទូលំទូលាយ គណនីទោលរបស់រតនាគារ ។
- ធ្វើអោយរលូនបន្ថែមទៀតនៃដំណើរការអនុវត្តថវិកា
- ពង្រឹងបន្ថែមទៀតនៅការគ្រប់គ្រងបំណុល

ដៃគូអភិវឌ្ឍន៍គាំទ្រយុទ្ធសាស្ត្រស្នូលរបស់រដ្ឋាភិបាល ដែលផ្តោតទៅលើការបញ្ចប់សកម្មភាពកំណែទំរង់ទាំងនោះនៅក្នុងផ្នែកភាគច្រើននៃឆ្នាំ 2007 ដែលនៅសល់ ។ ដៃគូអភិវឌ្ឍន៍ក៏គាំទ្រគោលបំណងរបស់រដ្ឋាភិបាលដើម្បីចាប់ផ្តើមផែនការអន្តរកាល និង ជាយុទ្ធសាស្ត្រ សំរាប់ដំណាក់កាលក្រោយទៀត ដោយមានគោលដៅចាប់ផ្តើមការអនុវត្តជំហានទី 2 នៅក្នុងឆ្នាំ 2008 ។ ផ្នែកកំណែទំរង់ជាយុទ្ធសាស្ត្រថ្មីមួយ គឺការគ្រប់គ្រងចំណូលពីប្រេង ហើយការងារនេះត្រូវឆ្លុះបញ្ចាំងក្នុងសូចនាករត្រួតពិនិត្យរួមគ្នាថ្មីមួយ សំរាប់កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

មានកិច្ចការដ៏សំខាន់ៗមួយចំនួនដែលត្រូវបំពេញនៅក្នុងកំណែទំរង់នៃដំណាក់កាលបន្ទាប់រួមមាន :

- បញ្ចប់សកម្មភាពនានា នៃជំហានទី 1 ដែលជាប់ទាក់ទងទៅនឹងសមាហរណកម្មថវិកា គោលនយោបាយប្រមូលចំណូល ការគ្រប់គ្រងសាច់ប្រាក់ ការធ្វើអោយរលូននៃដំណើរការអនុវត្តថវិកា និង ការពង្រឹងការគ្រប់គ្រងបំណុល ។

- កែលំអការជាប់ទាក់ទិនរបស់ក្រសួងសាមីនានាក្នុងគ្រប់ផ្នែកនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជ័យជំនះនៃជំហានទី 2 នឹងពឹងផ្អែកយ៉ាងខ្លាំងទៅលើកិច្ចការសំរបសំរួលដ៏មានប្រសិទ្ធភាពទាំងផ្នែកដំណើរការ និង ផ្នែកស្ថាប័ន ។

- ការដាក់អោយមានក្របខ័ណ្ឌគោលនយោបាយ និងស្ថាប័នដើម្បីគ្រប់គ្រងចំណូលពីប្រេង ។ ក្នុងចំណោមរាប់រយសកម្មភាពដែលបង្កើតអោយមានកម្មវិធីគ្រប់គ្រងកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ពិបាកនឹងរកសកម្មភាពទាំងឡាយណា ដែលសំខាន់ជាងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រងចំណូលពីប្រេង ។ លើសពីការអនុម័តគំនិតផ្តួចផ្តើមអំពីតម្លាភាពសំរាប់ឧស្សាហកម្មប្រមូលធនធាន (EITI) ដៃគូអភិវឌ្ឍន៍រំពឹងទុកថានឹងមានឯកសារជ្រើសរើស (Option Papers) អំពីការគ្រប់គ្រងចំណូលពីប្រេង ដែលត្រូវព្រាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ 2008 ។

- ការកែលំអសមត្ថភាព និង ការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ននៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង នៅក្រសួងសាមីនានា ដែលត្រូវការចាំបាច់ដើម្បីគាំទ្រដល់ការកែប្រែដ៏ច្រើនទៀត ក្នុងសកម្មភាពនានារបស់ជំហានទី 2 ។ បទពិសោធន៍ពីប្រទេសជាច្រើនបង្ហាញថា អវត្តមាននៃលក្ខខណ្ឌជាអប្បបរមាទាំងនេះ ធ្វើអោយចុះថយលទ្ធភាពនៃការអនុវត្តកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ ។

- ពង្រឹងតួនាទីរបស់រដ្ឋអំណាចត្រួតពិនិត្យ (អាជ្ញាធរសវនកម្មជាតិ និង សភា) ។ គន្លឹះសំរាប់បញ្ហានេះ គឺការកសាងសមត្ថភាព មូលដ្ឋានធនធាន និងឯករាជ្យភាពនៃអគ្គសវនករ និងដើម្បីសំរួលសមត្ថភាពនៃលេខាធិការដ្ឋានសភា ដើម្បីគាំទ្រគណៈកម្មការត្រួតពិនិត្យសំខាន់ៗ ។

ហាក់ដូចជាមានការសន្យាទាំងខាងនយោបាយ និង ការចាត់ចែងយ៉ាងបង្គួរ ហើយមានការយល់ស្របគ្នារបស់អ្នកដែលជាប់ទាក់ទិន អំពីជំហានទៅមុខទៀត ។ ភាពប្រឈមនានានៅតែមាន ប៉ុន្តែភាពប្រឈមទាំងនោះត្រូវបានទទួលស្គាល់ជាទូទៅជាមួយនឹងការយល់ព្រមព្រៀងអំពីទស្សនៈវិស័យដ៏ទូលំទូលាយនៃផ្លូវទៅអនាគត និងការបញ្ជាក់នៃជំហាននានាដែលត្រូវធ្វើអោយមានភាពជឿនលឿន ។ ហាក់ដូចជាមានឆន្ទៈទាំងក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសាមីនានា ដើម្បីកសាងសមត្ថភាពបច្ចេកទេសដែលចាំបាច់ដើម្បីដើរតាមផ្លូវកំណែទំរង់នេះ ។ ដៃគូអភិវឌ្ឍន៍សន្យាថាផ្តល់នូវហិរញ្ញប្បទានយ៉ាងច្រើន ដើម្បីទ្រទ្រង់កំណែទំរង់ដ៏សំខាន់ៗទាំងនេះ ។

ឧបសគ្គរាំងដ៏ចម្បងមួយក្នុងកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែជាភាពប្រឈមនានាក្នុងក្របខ័ណ្ឌរដ្ឋបាល និងធនធានមនុស្សជាមូលដ្ឋាន។ សំរាប់ប្រព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដ៏ទំនើបមួយមានប្រសិទ្ធភាព ត្រូវការក្របខ័ណ្ឌស្ថាប័នបំពេញបន្ថែម និង ការចាត់ចែងផ្នែកធនធានមនុស្ស ដែលគាំទ្រការគ្រប់គ្រងធនធានជាយុទ្ធសាស្ត្រនិងប្រតិបត្តិការ និង ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សមួយ ដែលលើកតំកើងផែនការ ការចាត់ចែង និង ការប្រើប្រាស់ធនធានមនុស្ស ។ ការងារនេះជាប់ទាក់ទងទៅនឹងការកែលំអប្រាក់បៀវត្សសំរាប់វិស័យសាធារណៈ ធ្វើអោយសមស្របការងារក្នុងវិស័យសាធារណៈ រៀបចំរចនាសម្ព័ន្ធឡើងវិញ ការវាយតំលៃលើការអនុវត្តន៍ការងារ និង ការកសាងសមត្ថភាពនៅក្នុងក្របខ័ណ្ឌថវិកាដែលបានអនុម័ត ។ អនុវត្តបាននូវក្របខ័ណ្ឌនេះ ត្រូវប្រើពេលវេលា និង ត្រូវការភាពជាអ្នកដឹកនាំដ៏សកម្មជាបន្ត និងការគាំទ្រដ៏ច្រើនពីស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវ គឺក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ការខំប្រឹងប្រែងមួយចំនួន ដើម្បីលើកទឹកចិត្តដល់កំណែទំរង់នានាខាងលើបានធ្វើឡើងតាមរយៈកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានការគាំទ្រដើម្បីធ្វើអោយមានភាពសមស្របចំពោះប្រព័ន្ធប្រាក់បៀវត្សបន្ថែម ការពិនិត្យឡើងវិញនៃមុខងារ ការដាក់បញ្ចូលនៃគំនិតផ្តួចផ្តើមបៀវត្សតាមការបំពេញការងារ (MBPI) និង ការគ្រប់ដណ្តប់ដោយគ្រប់ជ្រុងជ្រោយនៃប្រាក់បៀវត្ស រួមទាំងចំណាយផ្សេងៗ តាមរយៈតារាងបៀវត្ស ។ ដោយលើកលែងតែករណីនៃគំនិតផ្តួចផ្តើមផ្តល់បៀវត្សតាមការបំពេញការងារ (MBPI) នៅក្នុងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ គំនិតផ្តួចផ្តើមកំណែទំរង់ដទៃទៀតមិនបានជឿនលឿនទៅមុខដូចដែលបានគិតពីមុន ហើយកិច្ចពិភាក្សាត្រូវបានជាប់គាំង ។ ដៃគូអភិវឌ្ឍន៍មានឆន្ទៈនឹងជួយរដ្ឋាភិបាលលើការតាក់តែង និងអនុវត្តរបៀបវារៈកំណែទំរង់សេវាសាធារណៈ និង ធនធានមនុស្សដ៏គ្រប់ជ្រុងជ្រោយមួយ ហើយរំពឹងទុកថានឹងរកឃើញមធ្យោបាយនានាដើម្បីធ្វើអោយមានភាពជឿនលឿនឡើងវិញ លើបញ្ហាគន្លឹះនេះ ។

## កំណែទំរង់ការអភិវឌ្ឍន៍វិស័យឯកជន

ចាប់តាំងពីពេលដែលដាក់ចេញនូវក្របខ័ណ្ឌអភិវឌ្ឍន៍សំរាប់សហគ្រាសធុនតូច និង មធ្យម (SME) នៅដើមឆ្នាំ 2006 មានភាពជឿនលឿនក្នុងការលើកតំកើងការអភិវឌ្ឍន៍ និង បរិស្ថានអំណោយផលសំរាប់ទ្រទ្រង់សហគ្រាសធុនតូច និង មធ្យម ។ សហគ្រាសធុនតូចនិងមធ្យម មានលើសពី 99 ភាគរយ នៃសហគ្រាសទាំងអស់នៅកម្ពុជាហើយភាគច្រើននៅក្នុងវិស័យមិនផ្លូវការ ។ ការកែលំអបរិយាកាសអំណោយផលដល់សហគ្រាសធុនតូចជាង ដើម្បីអោយសហគ្រាសទាំងនោះរីកចំរើន វិនិយោគ និង បង្កើតចំណូល និង ការងារហើយផ្លាស់ចូលមកក្នុងសេដ្ឋកិច្ចផ្លូវការនឹងត្រូវជាការងារសំខាន់ក្នុងការខំប្រឹងប្រែងរួមគ្នាដើម្បីកាត់បន្ថយភាពក្រីក្រ ដោយគាំទ្រការធ្វើអោយសំបូរបែបនៃសេដ្ឋកិច្ច និង ផ្តោតកំណើនទៅក្នុងតំបន់ជនបទ ។

ធ្វើអោយរលូន និង ធ្វើអោយងាយស្រួលដល់ការចេញអាជ្ញាប័ណ្ណកំពុងតែប្រព្រឹត្តទៅ ។ ផែនការយន្តការពិនិត្យមើលឡើងវិញលើការផ្តល់អាជ្ញាប័ណ្ណត្រូវបានអនុម័ត ។ ការអនុវត្តន៍កំណែទំរង់នៃអាជ្ញាប័ណ្ណទាំងនោះដែលមានការប៉ះពាល់យ៉ាងខ្លាំងបំផុតដល់សហគ្រាសធុនតូចនិងមធ្យម គឺជាអាទិភាពមួយ ។ មានភាពជឿនលឿននៅក្នុងដំណើរការចុះបញ្ជីក្រុមហ៊ុននៅតាមបណ្តាខេត្ត ។ ការសាកល្បងត្រូវបានរៀបចំឡើងនៅក្នុងខេត្តជ្រើសរើសមួយចំនួន ។ ការអនុវត្តន៍ការិយាល័យបញ្ចមួយ (Single Window Office) នៅតាមខេត្តនានា នឹងកាត់បន្ថយកំរៃនៃការធ្វើអាជីវកម្មយ៉ាងច្រើន ។

នៅពេលដែលលក្ខខណ្ឌអនុគ្រោះជាង សំរាប់សហគ្រាសធុនតូច និង មធ្យមកំពុងត្រូវបានបង្កើតឡើង និងអនុវត្តនៅគ្រប់កំរិត ការអនុវត្តន៍ច្បាប់សហគ្រាសពាណិជ្ជកម្ម ជាពិសេសនៅតាមបណ្តាខេត្ត នៅតែមានភាពប្រឈម ។ ដើម្បីបង្កើនការលើកកំពស់សហគ្រាសធុនតូច និង មធ្យម បន្ទុកនៃចំណាយក្រៅផ្លូវការ និងការគេចពន្ធត្រូវតែដោះស្រាយ ពីព្រោះទាំងអស់នេះរាំងស្ទះដល់ការលូតលាស់នៃពាណិជ្ជកម្មស្របច្បាប់ ។ ដូចដែលក្របខណ្ឌនៃការអភិវឌ្ឍន៍បញ្ជាក់ប្រាប់ ផែនទីចង្អុលផ្លូវផ្តល់នូវសកម្មភាពនានា ដែលនឹងកែលំអការទទួលយកហិរញ្ញប្បទាន ។ ភាពជឿនលឿនច្រើនត្រូវសំរេចបាន ដូចជាការអនុម័តិទំរង់បែបបទរបាយការណ៍ហិរញ្ញវត្ថុដែលងាយស្រួល ។ ការទទួលបានឥណទានត្រូវបានកែលំអ និង ពង្រីក ។ ទោះបីជាយ៉ាងនេះក្តីឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលសមស្របដល់កំចីសំរាប់សហគ្រាសធុនតូច និង មធ្យម គួរតែត្រូវបង្កើតឡើង និង ការជឿនលឿនបន្តទៀតក្នុងកាចេញកម្មសិទ្ធិដីធ្លីគឺជាការសំខាន់បំផុត ពីព្រោះកម្មសិទ្ធិដីធ្លីនេះនឹងក្លាយជាវត្ថុបញ្ចាំដែលត្រូវការយ៉ាងខ្លាំងសំរាប់សហគ្រាសធុនតូច និង មធ្យម ជាពិសេសសហគ្រាសនានាដែលនៅក្នុងតំបន់ជនបទ។

## ពាណិជ្ជកម្ម

ក្នុងឆ្នាំកន្លងទៅនេះ វិស័យនាំចេញរបស់កម្ពុជាបានបន្តកើនឡើង ជាមួយនិងការរីកដុះដាលដោយចីរភាពនៃវិស័យទេសចរណ៍ និង វិស័យកាត់ដេរដ៏គួរកត់សំគាល់ ។ នេះពិតជាកំពុងផ្តល់នូវការលើកទុកចិត្តដែលថា កម្ពុជាអាចបន្តកំណើន ទោះបីជាប្រព័ន្ធកូតាវិស័យកាត់ដេរក្រោមកិច្ចព្រមព្រៀងតម្បាញច្រើនសណ្ឋាន (Multi-Fiber Agreement) បានបញ្ចប់ ។ ទោះបីយ៉ាងនេះក្តី ដូចបានលើកឡើងខាងលើ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសវៀតណាម នឹងផ្តល់ដល់ផលិតករនានាផ្នែកសំលៀកបំពាក់របស់កម្ពុជាទទួលនូវការប្រកួតប្រជែងពិបាកជាងមុន ហើយជោគជ័យរបស់ពួកគេពឹងយ៉ាងសំខាន់ទៅលើថ្លៃដើម និង ការចំណាយពេលសំរាប់ការធ្វើអាជីវកម្មនៅកម្ពុជា ។ ផ្អែកលើសមិទ្ធផលដែលមានពីមុន ផលចំណេញក្នុងផ្នែកនេះនៅតែមាន ។ ហានិភ័យដែលបង្ហាញប្រាប់ក៏បានបញ្ជាក់ម្តងទៀតផងដែរថា ចាំបាច់ត្រូវអោយមានការបង្កើនមុខទំនិញនាំចេញរបស់កម្ពុជាអោយបានសំបូរបែប ហើយការអភិវឌ្ឍន៍នូវសមត្ថភាពផ្គត់ផ្គង់របស់សហគ្រិននានា ក៏ដូចជាការធានានូវការសំរួលពាណិជ្ជកម្ម គឺមានសារៈសំខាន់ស្មើគ្នា ដើម្បីធ្វើអោយបានសំរេចការងារនេះ ។

ទាក់ទងនឹងការសំរួលពាណិជ្ជកម្ម វឌ្ឍនភាពទទួលបានក្នុងឆ្នាំកន្លងទៅនេះ ដោយមានការបង្កើតអង្គភាពគ្រប់គ្រងហានិភ័យមួយនៅទីចាត់ការគយ និង រដ្ឋាករ និង ការអនុម័តឯកសាររដ្ឋបាលតែមួយ (Single Administrative Document) ដែលនឹងសាកល្បងអនុវត្តន៍ក្នុងឆមាសទី 2 ឆ្នាំនេះ ។ លទ្ធផលសាកល្បងនៃឯកសារ និង រចនាសម្ព័ន្ធទាំងនេះ នឹងឋិតនៅលើការអនុវត្តន៍តាមរយៈ ឧទាហរណ៍ កិច្ចព្រមព្រៀងរដ្ឋបាលនានាក្នុងចំណោមស្ថាប័នពាក់ព័ន្ធទាំងអស់ស្តីអំពីនីតិវិធី និង គោលការណ៍ណែនាំសំរាប់អធិការកិច្ច និង ជំរះការត្រួតពិនិត្យនៃទំនិញនាំចេញ និង នាំចូល ។

ការដាក់អោយចាប់ផ្តើមប្រព័ន្ធគយស្វ័យតអាស៊ីគូដា (ASYCUDA) ក៏កំពុងមានភាពជឿនលឿនជាបន្តបន្ទាប់ ហើយឥទ្ធិពលជាវិជ្ជមានរបស់វា នឹងបណ្តាលអោយមានកំណើនចំណូលពន្ធគយ ការទទួលបាននូវស្ថិតិពាណិជ្ជកម្មគួរអោយទុកចិត្ត និងការកាត់បន្ថយនូវរយៈពេលមធ្យមនៃការជំរះការត្រួតពិនិត្យ ។ កំណែទំរង់យ៉ាងស៊ីជំរៅនានានៃប្រព័ន្ធគយ ដែលការអនុវត្តន៍ប្រព័ន្ធអាស៊ីគូដា (ASYCUDA) ត្រូវអោយមាន នឹងកំណត់បានផ្នែកដ៏សំខាន់មួយនៃផលចំណេញដែលរំពឹងទុក ។

ជាផ្នែកមួយនៃរបៀបវារៈគតិយុត្តរបស់រាជរដ្ឋាភិបាល សេចក្តីព្រាងច្បាប់លើសម្បទាន (Law on Concessions) និងសេចក្តីព្រាងច្បាប់លើពន្ធគយ (Law on Customs) ត្រូវបានដាក់ជូនរដ្ឋសភា រួចជាស្រេចហើយដៃគូអភិវឌ្ឍន៍រង់ចាំការពិនិត្យពិចារណារបស់សម័យប្រជុំពេញអង្គនៃរដ្ឋសភាយ៉ាងឆាប់រហ័សដែលអាចធ្វើទៅបាន ។

តំបន់សេដ្ឋកិច្ចពិសេសនៅបាវិត គឺជាតំបន់ទីមួយ ដែលបានបង្កើតការិយាល័យច្រកចេញ-ចូលតែមួយ (One-Stop Service Window) ដែលមានស្ថាប័នរដ្ឋាភិបាលចំនួនប្រាំ ដែលបានដាក់តំណាងរបស់ខ្លួននៅក្នុងការិយាល័យតែមួយ ។ ការិយាល័យច្រកចេញ-ចូលតែមួយនេះនឹងត្រូវបានបង្កើតឡើងនៅគ្រប់ពេលដែលតំបន់សេដ្ឋកិច្ចពិសេសថ្មីមួយមានដំណើរការ ។

នាដើមឆ្នាំនេះ សេចក្តីព្រាងលើកទីមួយ អំពីការសិក្សាវិនិច្ឆ័យសមាហរណកម្មពាណិជ្ជកម្ម 2007 (Diagnostic Trade Integration Study - DTIS) ត្រូវបានរៀងចំឡើងដោយម្ចាស់ជំនួយមួយក្រុម ដែលសំរបសំរួលដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម ។ ឯកសារនេះបានធ្វើបច្ចុប្បន្នកម្មទៅលើការសិក្សាវិនិច្ឆ័យសមារណកម្មពាណិជ្ជកម្មដែលបានចេញនៅឆ្នាំ 2002 ហើយវានឹងត្រូវផ្តល់អោយនូវចំណុចគៀងគរដើម្បីចាប់ផ្តើមការពិភាក្សាគោលនយោបាយ និង ការកំណត់អាទិភាពក្នុងចំណោមម្ចាស់ជំនួយនានា ដែលទាក់ទងទៅនឹងជំនួយដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។ គឺជាការសំខាន់ណាស់ ដែលថាឯកសារសិក្សាវិនិច្ឆ័យសមាហរណកម្មពាណិជ្ជកម្ម ឆ្នាំ 2007 ជាស្ពានមួយ គឺត្រូវមានគុណភាពខ្ពស់បំផុត ដើម្បីធានានូវឆន្ទៈគាំទ្រគ្រប់គ្រាន់ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ ។

ក្រសួងពាណិជ្ជកម្មក៏មានវឌ្ឍនភាពក្នុងការរៀបចំអោយមានអភិក្រមតាមវិស័យប្រសើរជាងមុន សំរាប់ជំនួយដែលទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ខណៈពេលដែលក្រសួងបានផ្តួចផ្តើមដំណើរការកំណែទំរង់ផ្ទៃក្នុង និង ពង្រឹងឡើងវិញនូវអនុគណៈកម្មការអភិវឌ្ឍន៍ពាណិជ្ជកម្ម ។ ថ្មីៗនេះ នាយកដ្ឋានគយ និង រដ្ឋាករ បានធ្វើបច្ចុប្បន្នកម្មផែនការទំនើបភាវូបនីយកម្ម និង កំណែទំរង់គយ ដែលពិនិត្យមើលនូវសមិទ្ធផលទាំងឡាយ និង កំណត់ទិសដៅសំរាប់ការរីកចំរើនបន្តទៀត ដោយផ្តល់ដល់នាយកដ្ឋានខ្លួនឯងផ្ទាល់ និង អ្នកផ្តល់ជំនួយដែលចាប់អារម្មណ៍ក្នុងការគាំទ្រផែនការនេះនូវវិថីឆ្ពោះទៅមុខសំរាប់អង្គភាពដ៏សំខាន់នេះ ។

ការសំរបសំរួលយ៉ាងជិតស្និទ្ធរវាងស្ថាប័នទាក់ទងនឹងពាណិជ្ជកម្មទាំងអស់ នឹងនៅតែជាមូលដ្ឋានគ្រឹះចំពោះតួនាទីរបស់រដ្ឋាភិបាលក្នុងការលើកកំពស់ការអភិវឌ្ឍន៍វិស័យឯកជន ។ ការងារនេះស្តែងឡើងនៅក្នុងរបៀបវារៈដែលនៅសេសសល់របស់កម្ពុជា អំពីកិច្ចការគតិយុត្តទាក់ទងនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

ផ្នែកផ្សេងៗទៀតដូចជា អនាម័យ និង ភូតគាមអនាម័យ (Sanitation and Phytosanitation - SPS) របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (Technical Barriers to Trade - TBT) ជាដើម អាចប្រែក្លាយជាការសំខាន់សំរាប់វិស័យនាំចេញដែលមានច្រើនមុខទំនិញ និង មានមូលដ្ឋានក្នុងតំបន់ជនបទ ហើយតំរូវអោយមានសហប្រតិបត្តិការធំធេងក្នុងចំណោមក្រសួងសាមីនានា ។

## សន្និដ្ឋាន និង បញ្ហានានាសំរាប់ពិភាក្សា

ប្រទេសកម្ពុជាទទួលបាននូវកំរិតស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចគួរអោយកត់សំគាល់ នាំមកជាមួយនូវអត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ចខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រ ហើយសមនឹងទទួលការកោតសរសើរអំពីលទ្ធផលទាំងនេះ ។ ទាំងអស់នេះបានឆ្លុះបញ្ចាំងអំពីឥទ្ធិពលរួមបញ្ចូលគ្នានៃការអនុវត្តន៍ដោយប្រុងប្រយ័ត្ន នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនានា និង កំណែទំរង់រចនាសម្ព័ន្ធផ្សេងៗ ចំពោះប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនានា និង កិច្ចខិតខំសំរួលការអភិវឌ្ឍន៏វិស័យឯកជន ការគាំទ្រខ្លាំងក្លាទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសពីសំណាក់ដៃគូអភិវឌ្ឍន៏នានា ។

ភាពប្រឈមឥឡូវនេះគឺការទាញយកប្រយោជន៍ពីបរិយាកាសដ៏រឹងមាំមាននេះ ដើម្បីធ្វើអោយមានការរីកចំរើនលើបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាអភិវឌ្ឍន៏ជាគន្លឹះនានា ដែលកម្ពុជាកំពុងប្រឈម ក្នុងគោលបំណងបង្កើតអោយមាននូវការវាយលុកយ៉ាងជ្រៅជាងមុននៅក្នុងការកាត់បន្ថយភាពក្រីក្រ និង ទទួលបានសមិទ្ធផលក្នុងគោលដៅអភិវឌ្ឍន៏សហស្សវត្សរបស់កម្ពុជា ។ តាមរយៈការយល់ឃើញនេះ ដៃគូអភិវឌ្ឍន៏សូមលើកឡើងនូវបញ្ហាមួយ ចំនួនក្នុងន័យពិភាក្សាដើម្បីស្ថាបនាដូចតទៅនេះ ហើយទស្សនៈរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាទាំងនេះនឹងត្រូវស្វាគមន៍បំផុត :

- ការរកឃើញប្រេងមានឥទ្ធិពលដ៏ធំចំបងដល់គោលនយោបាយ ទោះបីជាបរិមាណនៃប្រេងដែលអាចផលិតបានទាបច្រើនជាងការប៉ាន់ស្មានពីមុន ។ ភាពជឿនលឿនក្នុងការរៀបចំរបបច្បាប់ និយ័តភាព និងពន្ធដារគួរតែត្រូវបានធ្វើមុនពេលផលិតកម្មប្រេងជាក់ស្តែង ដើម្បីធានាថា ផ្ទះបាយបានរៀបចំស្រេចបាច់នៅពេលដែលត្រីស្រង់ចេញពីទឹក ។ មានបញ្ហាប្រហាក់ប្រហែលគ្នានេះ កើតមានក្នុងវិស័យដទៃទៀតដូចជា វិស័យរ៉ែ ។ តើអាទិភាពរបស់រដ្ឋាភិបាលក្នុងវិស័យទាំងនេះមានអ្វីខ្លះ ? ហើយដៃគូអភិវឌ្ឍន៏អាចជួយបានយ៉ាងដូចម្តេច ?

- ការចាត់ថ្នាក់ឥណទានអធិបតេយ្យដែលទទួលបានថ្មីៗនេះ បើកផ្លូវអោយរដ្ឋាភិបាលខ្ចីអំពីទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ។ នៅពេលដែលកំចីមួយចំនួនតូចដែលផ្អែកលើការប្រាក់ពាណិជ្ជកម្មសំរាប់គំរោងរចនាសម្ព័ន្ធដែលចំណេញខ្ពស់សមស្របនឹងចីរភាពបំណុល កំចីទាំងនោះនឹងបង្កអោយមានចំណាយច្រើនក្នុងការសងតំលៃសេវានៃបំណុល និង បង្វែរធនធានរបស់រដ្ឋាភិបាលដ៏កំរពីសកម្មភាពដទៃទៀត ។ តើទស្សនៈរបស់រដ្ឋាភិបាលអំពីការគិតគូរទាំងនេះមានអ្វីខ្លះ ?

- តំរូវអោយមានកំណែទំរង់ដ៏គ្រប់ជ្រុងជ្រោយមួយលើផ្នែកសេវាសាធារណៈ ដើម្បីទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ ក៏ដូចជាការកែលំអអភិបាលកិច្ច ។ តើត្រូវសំរបសំរួលយ៉ាងដូចម្តេច នៅពេលដែលមានទស្សនៈផ្សេងគ្នាអំពីទិសដៅជាទូទៅដែលត្រូវប្រកាន់យកដើម្បីអោយរាជរដ្ឋាភិបាលអាចកសាងសេវាសាធារណៈដែលប្រកបដោយប្រសិទ្ធភាពការងារដែលអាចជំនះភាពប្រឈមនានានៅក្នុងទសវត្សទី 21 ?

- កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងតែអភិវឌ្ឍន៏ល្អណាស់ ហើយការយកចិត្តទុកដាក់ក្នុងឆ្នាំខាងមុខនេះ គឺការបញ្ចប់សកម្មភាពនានាក្នុងជំហានទី 1 (Platform 1) និង ចាប់ផ្តើមកសាងមូលដ្ឋាន សំរាប់ជំហានទី 2 (Platform 2 ) ។ កំណែទំរង់នឹងត្រូវពឹងផ្អែកកាន់តែខ្លាំងឡើងៗ លើការចូលរួមដ៏សកម្មពីសំណាក់ក្រសួងសាមីនានា។ តើរដ្ឋាភិបាលមើលឃើញដំណើរការនេះស្តែងឡើងយ៉ាងដូចម្តេច ?

- កំណែទំរង់នៃការអភិវឌ្ឍន៏វិស័យឯកជន គឺមានសារៈសំខាន់ណាស់ ដើម្បីពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច និង ពង្រឹងចំណងផ្សារភ្ជាប់រវាងកំណើន និង ការកាត់បន្ថយភាពក្រីក្រ ។ មានភាពជឿនលឿនក្នុងការកែលំអបរិស្ថានពាណិជ្ជកម្ម និង ការអនុវត្តកំណែទំរង់នៃការសំរួលពាណិជ្ជកម្ម ។ ទោះបីជាយ៉ាងនេះក្តី ចំណាយខ្ពស់នៃកំរៃក្រៅផ្លូវការ និង កង្វះក្របខ័ណ្ឌពេលលេញមួយនៃច្បាប់ពាណិជ្ជកម្មនានា រួមទាំងច្បាប់ប្រឆាំងអំពើពុករលួយ កំពុងតែរារាំងភាពជឿនលឿន ។ តើអ្វីដែលរដ្ឋាភិបាលចាត់ទុក ថាជាជំហានដ៏សំខាន់ៗបំផុត ដើម្បីដោះស្រាយបញ្ហាទាំងនោះ ក្នុងកំឡុងឆ្នាំខាងមុខ ?

ដៃគូអភិវឌ្ឍន៏អបអរសាទររាជរដ្ឋាភិបាលនូវជ័យជំនះដែលទទួលបាន ហើយយើងនឹងនៅតែប្តេជ្ញាបំពេញការងារយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ដើម្បីសំរេចអោយបាននូវរបៀបវារៈកំណែទំរង់អភិវឌ្ឍន៏របស់រាជរដ្ឋាភិបាល ។ យើងរំពឹងទុកនូវកិច្ចពិភាក្សាក្នុងន័យស្ថាបនា និង ប្រកបដោយផ្លែផ្កានៅឯវេទិកាសហប្រតិបត្តិការ និង អភិវឌ្ឍន៏កម្ពុជាលើកទី ១ នេះ ។